# របាំសហសម័យខ្មែរក្នុងបរិបទអាស៊ី

ប្រទេសកម្ពុជាប្រកបដោយវប្បធម៌ដ៏សម្បូរបែប មានទម្រង់សិល្បៈទស្សនីយភាពជាង២០ទម្រង់ ដូចជា តន្ត្រី ល្ខោន តុក្កតា ល្ខោនស្បែក និងរបាំ។ល។ នាបច្ចុប្បន្នកាលខ្មែរយើងមានរបាំព្រះរាជទ្រព្យឬរបាំក្បាច់បុរាណ របាំប្រពៃណី របាំប្រជាប្រិយ និងរបាំសហសម័យ។

អត្ថបទនេះ នឹងផ្តោតទៅលើរបាំសហសម័យខ្មែរក្នុងបរិបទអាស៊ី ក្រោយពីមានការសង្កេតលើគណៈកម្មការរបាំអាស៊ី ដែលជាគម្រោងនិងសកម្មភាពការងារអន្តររដ្ឋាភិបាលនៃបណ្តាប្រទេសក្នុងទ្វីបអាស៊ី និងសាធារណរដ្ឋកូរ៉េ។ ដូចជាឈ្មោះរបស់គម្រោងនេះបានបង្ហាញ គណៈកម្មការរបាំអាស៊ី ត្រូវបានគេសន្មតជាគ្របដណ្តប់គ្រប់ទម្រង់របាំទាំងអស់ដោយអព្យាក្រឹតភាព។ ប៉ុន្តែជាក់ស្តែង សកម្មភាពការងារភាគច្រើនគឺពាក់ព័ន្ធនឹងអំពីរបាំសហសម័យ ច្រើនជាងប្រភេទឬទម្រង់របាំដទៃទៀតនៃប្រទេសក្នុងទ្វីបអាស៊ីនិងប្រទេសកូរ៉េ។

យោងទៅលើការរាយការណ៍ និងបទបង្ហាញពីស្ថានភាពរបាំក្នុងប្រទេសរបស់គេរៀងៗខ្លួននាសម័យប្រជុំនៃគណៈកម្មការរបាំអាស៊ី នាពេលថ្មីៗនេះ យើងឃើញថាស្ថានភាពប្រទេសនីមួយៗពាក់ព័ន្ធនឹងរបាំ គឺខុសៗគ្នាទៅតាមទស្សនៈ គំនិត និងសមត្ថភាពបច្ចេកវិទ្យានិងហិរញ្ញវត្ថុរបស់គេ។

ជារួម ជាពិសេសក្នុងរយៈពេលនៃការរាតត្បាតនៃជម្ងឺកូវីដ-១៩ ការសម្តែងរបាំទាំងអស់ត្រូវបានគេកែសម្រួលមកធ្វើតាមរយៈការផ្សព្វផ្សាយឌីជីថល។ ក្នុងបរិបទនេះ របាំសហសម័យរបស់កម្ពុជា គឺដើរក្រោយគេជាងរបាំសហសម័យនៃបណ្តាប្រទេសក្នុងទ្វីបអាស៊ីនិងកូរ៉េ ដោយសារកត្តានិងមូលហេតុមួយចំនួន។ ក្នុងទស្សនៈសកល និន្នាការ និងទិសដៅ បច្ចុប្បន្ននៃរបាំអាស៊ី គឺអ្វីៗសុទ្ធតែថ្មី ផ្តោតទៅលើយុវវ័យ និងឈរលើមូលដ្ឋានបច្ចេកវិទ្យាទំនើប។

បច្ចេកវិទ្យាទំនើបនិងប្រព័ន្ធផ្សព្វផ្សាយឌីជីថល បានផ្តល់ឲ្យរបាំសហសម័យក៏ដូចជាទស្សនិកជននូវទិដ្ឋភាពជាច្រើនរួមទាំងបទពិសោធន៍ថ្មីៗ។ អត្ថប្រយោជន៍នៃបទពិសោធន៍ថ្មីគឺផ្តល់ឲ្យទស្សនិកជននូវពហុប្រព័ន្ធផ្សព្វផ្សាយថ្មី។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

អត្ថបទ៖ របាំសហសម័យខ្មែរក្នុងបរិបទអាស៊ី

យ៉ាងណាមិញ មានទស្សនៈថា «ល្ខោននៅក្នុងភាពយន្ត មិនមែនជាល្ខោន ហើយភាពយន្តអំពីល្ខោនក៏មិនមែនជាភាពយន្តដែរ»។ យើងក៏អាចសន្មតបានដូចគ្នាថា «របាំនៅក្នុងភាពយន្ត មិនមែនជារបាំ ហើយភាពយន្តអំពីរបាំក៏មិនមែនជាភាពយន្តដែរ»។

យើងគួរកត់សម្គាល់ថា កាលណាគេនិយាយអំពីរបាំ គឺប្រទេសភាគច្រើន មានកូរ៉េ និងសឹង្ហបូរីជាដើមសង្កត់ធ្ងន់ទៅលើស្ថានភាពពាក់ព័ន្ធនឹងរបាំសហសម័យ ដោយប្រើបណ្តាញបច្ចេកវិទ្យាទំនើប និងគំនិតថ្មី ប្រកបដោយភាពច្នៃប្រឌិតជឿនលឿនបំផុត។

សម្រាប់ប្រទេសកម្ពុជា ភាពខ្លាំងពិតគឺស្ថិតនៅក្នុងសិល្បៈបុរាណនិងប្រពៃណីមិនមែនខ្លាំងក្នុងសិល្បៈសហសម័យឡើយ។ លើសពីនេះទៅទៀត បេតិកភណ្ឌសម្បត្តិវប្បធម៌អរូបីគឺជាបេតិកភណ្ឌសម្បត្តិវប្បធម៌ខ្មែរបុរាណ។

ជាទស្សនៈសំខាន់និងចាំបាច់ខ្ពស់ របាំអាស៊ីក្នុងគន្លងថ្មី ត្រូវមានភាពនិងលក្ខណៈអាស៊ី ក៏ដូចជាអត្តសញ្ញាណនិងតម្លៃអាស៊ីដូច្នោះដែរ។ នៅក្នុងបរិបទសកលភាវូបនីយកម្ម និងតំបន់ភាវូបនីយកម្ម យើងត្រូវគិតជាសកល តែធ្វើសកម្មភាពជាជាតិ ក៏ដូចជាទិសស្លោកមួយថា "បុរាណមិនយឺត ឯសម័យមិនបរទេស»។

នៅកម្ពុជា អ្វីដែលបុរាណ មានឫសគល់ជ្រៅ ដែលខ្មែរអាចទទួលយកបានច្រើនជាងអ្វីដែលសម័យឬថ្មី។ នៅពេលដែលគេធ្វើអ្វីពាក់ព័ន្ធនឹង "បុរាណ" គឺគេនិយាយអំពីប្រព័ន្ធ និងការរំពឹងទុក ជាបទដ្ឋាន។ ពោលគឺអ្វីដែលទស្សនិកជនធ្លាប់បានស្គាល់រួចមកហើយ។ ដូច្នេះ គេអាចពេញចិត្តនិងទទួលយកបាន ឧទាហរណ៍ បទពិសោធន៍របាំឬតន្ត្រី។

ប្រពៃណីដែលមានភាពរស់រវើក មានភាពទាក់ទាញ និងមានអត្ថន័យ នឹងត្រូវបានទស្សនិកជនគាំទ្រជាធម្មជាតិ។ យុវវ័យជំនាន់ក្រោយនាបច្ចុប្បន្នកាល ក្រោមលក្ខខណ្ឌនៃនិន្នាការសកល ប្រព័ន្ធអ៊ិនធើណែត ភាពជឿនលឿននៃបច្ចេកវិទ្យា និងលំហូរដែលមិនអាចទប់បាននៃវប្បធម៌បរទេស គឺជាមាគ៌ាឆ្ពោះទៅមុខនាពេលអនាគត។

តើយើងត្រូវធ្វើដូចម្តេចដើម្បីលើកទឹកចិត្តនិងជំរុញនវានុវត្តន៍ ក្នុងគំនិតគិតគូរដោយ មិនពាំងនិងមិនឲ្យរាំងស្ទះ? តើយើងត្រូវធ្វើដូចម្តេចដើម្បីការពារប្រពៃណី និងជំរុញបរិយាប័ន្ន ហើយនៅក្នុងពេលជាមួយគ្នា គាំទ្រនវានុវត្តន៍? ទាំងនេះគឺជាសំណួរដ៏សមហេតុសមផល ស្របនឹងពេលដែលយើងឈានទៅមុខនិងរកដំណោះស្រាយ៕

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



របាំសហសម័យនៅប្រទេសកម្ពុជា (ប្រភព៖ Channa)



របាំសហសម័យនៅប្រទេសកម្ពុជា (ប្រភព៖ Channa)

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



របាំសហសម័យនៅប្រទេសកូរ៉េខាងត្បូង (ប្រភព៖ Critical Stages)



របាំសហសម័យនៅប្រទេសតៃវ៉ាន់ (ប្រភព៖ Time Out)

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង